UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# បរិបទអន្តរជាតិ នៃសិទ្ធិខាងការប្រជុំដោយសន្តិវិធី

ការបង្ហាញនៅក្នុងសិក្ខាសាលាជាតិ លើសេចក្តីព្រាងច្បាប់ស្តីពីការប្រជុំដោយសន្តិវិធី
នៅទីក្រុងភ្នំពេញ ថ្ងៃទី៩-១០ ខែកុម្ភៈ ឆ្នាំ២០០៦

---

**ម៉ារ៉ូ តិកឃិន**
នាយិកា នៃការិយាល័យ
ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

ខ្ញុំសូមថ្លែងអំណរគុណ ដែលបានអញ្ជើញយើងខ្ញុំចូលរួមក្នុងសិក្ខាសាលានេះ យើងខ្ញុំសង្ឃឹមថា នេះគឺជាការពិគ្រោះយោបល់មួយ ក្នុងចំណោមការពិគ្រោះយោបល់ជាសាធារណៈច្រើនទៀត អំពីច្បាប់ដ៏សំខាន់នេះ ។

សិក្ខាសាលានេះគឺជាជំហានមួយឆ្ពោះទៅការរៀបបង្កើតច្បាប់ជាតិមួយថ្មីសំរាប់ប្រទេសកម្ពុជា ស្តីពីការប្រជុំដោយសន្តិវិធី ។ កម្ពុជាត្រូវការច្បាប់ល្អៗច្រើន ហើយប្រទេសនេះក៏ត្រូវការផងដែរនូវច្បាប់ដែលមានភាពយុត្តិធម៌ ។ ច្បាប់ឆ្នាំ១៩៩១ បច្ចុប្បន្ននេះ ត្រូវបានមតិទូទៅយល់ថាហួសសម័យ និងមានការខ្វះចន្លោះច្រើន ជាពិសេសច្បាប់នេះមិនស្របនឹងបញ្ញត្តិនៃរដ្ឋធម្មនុញ្ញកម្ពុជា ឬបទដ្ឋានអន្តរជាតិ ដូចមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ដែលកម្ពុជាគឺជារដ្ឋភាគីមួយ ។

នៅពេលជាមួយគ្នានេះដែរ ស្ថានការណ៍ទាក់ទងនឹងការអនុវត្តន៍សិទ្ធិខាងការប្រជុំដោយសន្តិវិធីបានលេចចេញនូវកង្វល់ជាច្រើន ។ ការប្រើប្រាស់សិទ្ធិនេះ ត្រូវបានបដិសេធជាញឹកញាយ ដោយមិនមានមូលហេតុ

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cohchr@online.com.kh Website: http://cambodia.ohchr.org

ត្រឹមត្រូវ ។ នៅពេលដែលបាតុកម្ម ឬការប្រជុំធ្វើឡើងដោយគ្មានការអនុញ្ញាត ជារឿយៗតែងកើតមានការប្រើប្រាស់កំលាំងហួសប្រមាណទៅលើបាតុករ ឬអ្នកដទៃទៀត ។ល ។ ច្បាប់ដែលកំពុងអនុវត្ត ពិតជាមិនមានបញ្ញត្តិការពារស្របតាមរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិ ដូច្នេះច្បាប់នេះត្រូវតែជំនួសដោយច្បាប់ថ្មី ។

ចំណុចចាប់ផ្តើមសំរាប់ការធ្វើច្បាប់ថ្មីណាមួយ ត្រូវតែពិនិត្យទៅលើបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិទាំងនេះ ហើយយើងគួរចងចាំនៅថ្ងៃនេះ នៅទីនេះផងដែរ អំពីបញ្ញត្តិដែលចែងថា ៖

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញចែងថា ៖

" ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ " ។

ម្យ៉ាងវិញទៀត មាត្រា៣៧ ចែងថា "សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធីត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់" ។

បទបញ្ញត្តិរដ្ឋធម្មនុញ្ញទាំងនេះ ត្រូវតែដើរទន្ទឹមគ្នាជាមួយបទដ្ឋានអន្តរជាតិស្តីពីការប្រជុំដោយសន្តិវិធីដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសន្ធិសញ្ញាដទៃទៀតដែលសន្ធិសញ្ញាទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិកម្ពុជា ។ មាត្រា២១ នៃកតិកាសញ្ញានេះ ចែងថា ៖

"សិទ្ធិប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់ ។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ" ។

សមាជិកសង្គមទាំងអស់ អាចប្រើប្រាស់សិទ្ធិខាងការប្រជុំដោយស្មើរភាពគ្នា ដូច្នេះហើយសិទ្ធិនេះក៏ត្រូវបានទទួលស្គាល់ និងការពារនៅក្នុងមាត្រា៥ (៩ ) នៃអនុសញ្ញាអន្តរជាតិស្តីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងមាត្រា១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។ វាក៏បានបញ្ជាក់ផងដែរនៅក្នុងមាត្រា៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលការពារសិទ្ធិបង្កើតសហជីព ។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បញ្ជាក់យ៉ាងច្បាស់ថា ជាគោលការណ៍ប្រជាពលរដ្ឋគ្រប់រូបអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនខាងការប្រជុំដោយសន្តិវិធី ដោយគ្មានការរិតត្បិតណាមួយមិនសមហេតុផល ។ ប្រសិនបើការរិតត្បិតគឺជាការចាំបាច់ត្រូវ (១) ដាក់ការរិតត្បិតស្របទៅតាមច្បាប់កំណត់ (២) ដើម្បីគោលបំណងណាមួយ ដែលមានចែងក្នុងមាត្រា២១ (៣) ដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីសំរេចគោលបំណងនេះ ។ គេអាចនិយាយម្យ៉ាងទៀតថា ការរិតត្បិតលើការប្រជុំដោយសន្តិវិធី គឺជាការលើកលែង វាមិនអាចជាវិធានច្បាប់បានទេ ។ ការជ្រៀតជ្រែកណាមួយទៅលើសិទ្ធិខាងការប្រជុំដោយសន្តិវិធី ត្រូវតែមានហេតុផលច្បាស់លាស់ និងមានសមាមាត្រសំរាប់គោលបំណងនោះ ។

ភារកិច្ចចំពោះមុខយើងនៅថ្ងៃនេះ គឺត្រូវធ្វើយ៉ាងណា ដើម្បីអនុវត្តសិទ្ធិទាំងអស់ដែលមានចែងក្នុងមាត្រា២១ និងមាត្រា៣១ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញ ដើម្បីធានាថា ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនខាងការប្រជុំដោយសន្តិវិធីនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

ការប្រជុំដោយសន្តិវិធី គឺជាកត្តាមួយដ៏សំខាន់ក្នុងសង្គមប្រជាធិបតេយ្យ វាគឺជាលទ្ធផលដែលទទួលបានពីសេរីភាពខាងការបញ្ចេញយោបល់ និងការសំដែងមតិ សិទ្ធិនេះត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ ។ ប្រជាពលរដ្ឋដែលមានយោបល់មុតមាំលើអ្វីមួយ ឬមិនយល់ស្របជាមួយរដ្ឋាភិបាលលើបញ្ហាជាក់លាក់មួយចំនួន ត្រូវបានអនុញ្ញាតឱ្យសំដែងមតិ ឬការជំទាស់របស់ខ្លួនដោយចំហរជាសាធាណៈ ប្រសិនបើគេចង់ប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានពេញលេញ ក្នុងការសំដែងមតិដោយសេរី ។ បាតុកម្មជាច្រើនមិនជាប់ពាក់ព័ន្ធនឹងរឿងគណបក្សនយោបាយទេ ។ ប៉ុន្តែបើទោះជាមានជាប់ទាក់ទងនឹងរឿងនយោបាយក៏ដោយ ក៏រដ្ឋាភិបាលមួយដែលរឹងមាំ កើតឡើងពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ និងមានការទទួលខុសត្រូវ មិនមានអ្វីត្រូវភ័យខ្លាចចំពោះការប្រើប្រាស់សិទ្ធិដែលរដ្ឋធម្មនុញ្ញបានការពារឡើយ ដែលនេះគឺជាការបំពេញមុខងារចាំបាច់ក្នុងលិទ្ធិប្រជាធិបតេយ្យ ក្នុងការអនុញ្ញាតឱ្យប្រជាពលរដ្ឋគ្រប់រូបសំដែងមតិ ពីការមិន

ពេញចិត្តរបស់ខ្លួន ។ ជាការពិតណាស់ រដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការរក្សាឱ្យមានការជជែកវែកញែក ដោយសន្តិវិធី និងការទិទៀនក្នុងន័យស្ថាបនា ដើម្បីឱ្យសង្គមបានល្អប្រសើរឡើង ។ ការប្រជុំដោយសន្តិវិធី គឺជាផ្នែកមួយដែលគេទទួលយក នៅក្នុងកិច្ចដំណើរការប្រជាធិបតេយ្យធម្មតា និងសំខាន់សំរាប់ការចូលរួម ប្រកបដោយប្រសិទ្ធិភាព ពីសំណាក់ប្រជាពលរដ្ឋ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក្នុងប្រទេសរបស់ខ្លួន ។

ទន្ទឹមគ្នានេះដែរ សំខាន់ត្រូវដឹងថា ច្បាប់អន្តរជាតិទទួលស្គាល់សិទ្ធិខាងការប្រជុំ កាលបើការប្រជុំ នោះធ្វើឡើងដោយ*សន្តិវិធី* ដោយហេតុនេះហើយទើបកតិកាសញ្ញាអនុញ្ញាតឱ្យមានការរិតត្បិត ដើម្បីការពារ សណ្តាប់ធ្នាប់សាធារណៈ ។ បាតុកម្មទាំងឡាយណា ដែលក្រោយមកក្លាយជាភាពចលាចល និងអំពើហឹង្សា គឺ នាំឱ្យខូចប្រយោជន៍ដល់បាតុករ ព្រោះវានាំឱ្យរំខានដល់អាជ្ញាធរ ដូច្នោះហើយជនណាដែលអនុវត្តសិទ្ធិខាង ការប្រជុំត្រូវមានការទទួលខុសត្រូវ ធ្វើយ៉ាងណាឱ្យបាតុកម្មនោះប្រព្រឹត្តទៅដោយសន្តិវិធី និងស្របទៅតាម ច្បាប់ ។ កាលបើពួកគេប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវនេះហើយ អាជ្ញាធរមិនចាំបាច់ធ្វើការរិតត្បិតលើការ អនុវត្តសិទ្ធិនេះឡើយ ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សូមស្វាគមន៍ដល់សិក្ខា សាលានេះដែលបានផ្តល់ឱកាសឱ្យចូលរួមក្នុងការជជែកវែកញែកក្នុងន័យស្ថាបនាលើសេចក្តីព្រាងច្បាប់នេះ ហើយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចពិភាក្សាក្នុងពេលពីរថ្ងៃនេះ នឹងផ្តល់ឱ្យមានភាពប្រសើរឡើងថែម ទៀតនៅក្នុងការព្រាងច្បាប់នេះ ដើម្បីធានាថាច្បាប់នេះស្របនឹងបទដ្ឋាននានា ដែលមានចែងនៅក្នុងរដ្ឋ ធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ សេចក្តីព្រាងច្បាប់នេះ ស្ថិតក្នុងស្ថានភាពបច្ចុប្បន្ននេះ បើទោះជា មានការពេញចិត្តលើទិដ្ឋភាពខ្លះក្តី ក៏នៅតែធ្វើឱ្យការិយាល័យយើងខ្ញុំមានការព្រួយបារម្ភអំពីទិដ្ឋភាពសំខាន់ៗ មួយចំនួនទៀតដែរ ។ ឧទាហរណ៍ យើងខ្ញុំយល់ថាប្រព័ន្ធជូនដំណឹងមានលក្ខណៈសមស្របជាងប្រព័ន្ធសុំការ អនុញ្ញាត ។ ម្យ៉ាងវិញទៀត ព័ត៌មានដែលគេតម្រូវឱ្យអ្នករៀបចំធ្វើបាតុកម្មផ្តល់ ដើម្បីបានការអនុញ្ញាត រួម មានខ្លឹមសារបដា និងសញ្ញាផ្សេងៗ គឺវិសមិតភាពទៅនឹងការធានាសិទ្ធិសេរីភាពក្នុងការបញ្ចេញយោបល់ និង ការសំដែងមតិ ។ ហើយយើងខ្ញុំមានការព្រួយបារម្ភថា របបនៃការផ្តន្ទាទោសទៅលើអ្នករៀបចំធ្វើបាតុកម្ម ចំពោះការរំលោភច្បាប់ គឺមានលក្ខណៈធ្ងន់ធ្ងរជាងច្បាប់ឆ្នាំ១៩៩១ ។

យើងខ្ញុំសូមស្នើយ៉ាងទទូចដល់សិក្ខាកាមទាំងអស់ ក្នុងសិក្ខាសាលានេះ និងក្នុងសិក្ខាសាលាដទៃទៀត ដើម្បីធានាថាសេចក្តីព្រាងច្បាប់នេះ នៅគ្រប់ទិដ្ឋភាពទាំងអស់ ស្របតាមអត្ថបទ និងស្មារតីនៃរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិនានា ដែលប្រទេសកម្ពុជាគឺជារដ្ឋភាគី ។ វាជាការសំខាន់ណាស់ដែលថា កិច្ចដំណើរការនេះមិនត្រូវធ្វើប្រញាប់ប្រញាល់ពេកទេ ហើយត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ សំរាប់កិច្ចដំណើរការពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវ ។ នៅក្នុងប្រទេសជាច្រើន ច្បាប់ដូចនេះ គេត្រូវដាក់ឱ្យមានការពិភាក្សាជាសាធារណៈរយៈពេលយូរ និងមានការជជែកដេញដោលខ្លាំងបំផុត នៅក្នុងពេលប្រជុំសភា ដើម្បីធានាឱ្យច្បាប់នេះអាចទទួលយកបានគ្រប់ទិដ្ឋភាព និងមានការគាំទ្រពីសាធារណជន ។ ពិតណាស់ វាអាចកើតមានបាតុកម្មសាធារណៈគាំទ្រនិងប្រឆាំងច្បាប់នេះ ដែលនេះបង្ហាញឱ្យឃើញពីហេតុដែលការប្រជុំដោយសន្តិវិធី គឺជាផ្នែកមួយសំខាន់នៃសង្គមប្រជាធិបតេយ្យ ។

ការិយាល័យឧត្តមស្នងការប្រចាំនៅកម្ពុជា និងនៅក្រុងហ្សឺណែវត្រៀមខ្លួនជាស្រេច ដើម្បីផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាល ធ្វើការកែលំអរសេចក្តីព្រាងច្បាប់នេះ ។

នេះគឺជាឱកាសមួយដ៏មានតំលៃ ដើម្បីអនុម័តច្បាប់ល្អមួយសំរាប់ប្រទេសកម្ពុជា ដែលនេះគឺជាសារមួយបញ្ជាក់ប្រាប់ពិភពលោកថា ប្រទេសកម្ពុជាគោរពសិទ្ធិមនុស្ស ដោយរួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញយោបល់ និងសំដែងមតិ និងអនុញ្ញាតឱ្យប្រជាពលរដ្ឋរបស់ខ្លួនអនុវត្តសិទ្ធិទាំងនេះ នៅក្នុងសង្គមមួយ ដែលបើកចំហរ និងដោយសេរីជាមួយសង្គមដទៃទៀត ។

សូមអរគុណ ។